ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខៈ ០០៦/២០ គ.ម.ក./ប្រ.ក.

# ប្រកាស
## ស្តីពី
## ការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ

* * * * *

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០០៩/១៧ គ.ម.ក./ប្រ.កចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ
- បានឃើញប្រកាសលេខ ០០៧/១៨ គ.ម.ក./ប្រ.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម
- បានឃើញប្រកាសលេខ ០០៥/១៦ គ.ម.ក./ប្រ.កចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ស្តីពីវិនិយោគិនគុណវុឌ្ឍិក្នុងវិស័យមូលបត្រ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងគ្រប់គ្រងការបោះផ្សាយលក់មូលបត្របំណុលនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់វិនិយោគិនគុណវុឌ្ឍិ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាព និងតម្លាភាព។

### ប្រការ ២.- គោលដៅ

ប្រកាសនេះមានគោលដៅកំណត់អំពីលក្ខខណ្ឌ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ អនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

### ប្រការ ៣.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការបោះផ្សាយលក់មូលបត្របំណុលនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់តែវិនិយោគិនគុណវុឌ្ឍិ។ មូលបត្របំណុលដែលបោះផ្សាយលក់នេះត្រូវធ្វើការផ្ទេរទៅវិនិយោគិនដែលជាវិនិយោគិនគុណវុឌ្ឍិប៉ុណ្ណោះ។

### ប្រការ ៤.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងក្នុងប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

១- **ច្បាប់** សំដៅដល់ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២-**វិនិយោគិនគុណវុឌ្ឍិ** សំដៅដល់វិនិយោគិនជាស្ថាប័ន និងវិនិយោគិនធនវុឌ្ឍិ ដូចមានចែងក្នុងប្រកាសស្ដីពីវិនិយោគិនគុណវុឌ្ឍិក្នុងវិស័យមូលបត្រ ដើម្បីចូលរួមក្នុងការបោះផ្សាយលក់មូលបត្របំណុលអនុលោមតាមប្រកាសនេះ។

៣-**អនុក្រឹត្យ** សំដៅដល់អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

## ជំពូកទី ២

## លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្របំណុល

### ប្រការ ៥.- ប្រភេទមូលបត្របំណុលដែលធ្វើសំណើលក់

មូលបត្របំណុលដែលត្រូវធ្វើសំណើលក់អនុលោមតាមប្រកាសនេះ សំដៅដល់មូលបត្របំណុលដូចបានកំណត់ក្នុងប្រការ ៣ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

### ប្រការ ៦.- ការដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្របំណុល

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិត្រូវដាក់ពាក្យស្នើសុំដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ ដើម្បីស្នើសុំការអនុញ្ញាតលើសំណើបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ **គ.ម.ក.**។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានអប្បបរមាដូចមានចែងក្នុងប្រការ ១១ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់បុគ្គលដែលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន។

### ប្រការ ៧.- លក្ខខណ្ឌតម្រូវ

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១- ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

២- មានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលឱ្យបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ។

៣- មានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម រយៈពេល ២(ពីរ) ឆ្នាំនៃឆ្នាំជាប់ពន្ធចុងក្រោយ ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ បុគ្គលដាក់ពាក្យស្នើសុំអាចផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ករណីបុគ្គលនោះដាក់ពាក្យស្នើសុំនៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស។

៤- ទទួលបានការបញ្ជាក់ជាមុនអំពីការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល និងការដាក់តម្លៃមូលបត្របំណុលពីទីផ្សារមូលបត្រប្រតិស្រុត។

បុគ្គលដាក់ពាក្យស្នើសុំត្រូវបានលើកទឹកចិត្តឱ្យអនុវត្តអភិបាលកិច្ចសាជីវកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

### ប្រការ ៨.- លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណមានការធានា

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានាត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១- បំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

២- មានវត្ថុធានាដែលត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- មានវិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបញ្ជាក់ថាវត្ថុធានានោះមិនជាប់ប្រាតិភោគណាមួយឡើយ។

- ករណីវត្ថុធានាជាអចលនវត្ថុ ឬសិទ្ធិជួលអចិន្ត្រៃយ៍ តម្លៃនៃវត្ថុធានានោះត្រូវវាយតម្លៃដោយក្រុមហ៊ុនវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

៣- ចំនួនទឹកប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុលត្រូវមានតម្លៃអតិបរមាស្មើនឹង ៧០ (ចិតសិប) ភាគរយ នៃតម្លៃវត្ថុធានា គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

៤- វត្ថុធានាត្រូវរក្សាទុកនៅភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានាត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១- បំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ។

២- ត្រូវមានបុគ្គលធានាដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** ហើយបុគ្គលធានានោះត្រូវធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី**គ.ម.ក.**។

**ប្រការ ៩.- ការបោះផ្សាយលក់មូលបត្របំណុលរបស់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រ**

បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ហើយមានបំណងស្នើសុំបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ ត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៧ ឬប្រការ ៨ នៃប្រកាសនេះ លើកលែងលក្ខខណ្ឌរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ និងចំណុចទី ៤ នៃប្រការ ៧ នៃប្រកាសនេះ។

បុគ្គលដែលបានបោះផ្សាយលក់មូលបត្របំណុល ហើយមានបំណងស្នើសុំបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ អាចត្រូវបានលើកលែងចំណុចទី៣ និងចំណុចទី ៤ នៃប្រការ ៧ នៃប្រកាសនេះបាន ករណីបុគ្គលនេះបានដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិមុនរយៈពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃនៃឥណប្រតិទាននៃមូលបត្របំណុលដែលបានបោះផ្សាយ។

**ប្រការ ១០.- ឯកសារតម្រូវសម្រាប់ស្នើសុំបោះផ្សាយលក់មូលបត្របំណុល**

បុគ្គលដាក់ពាក្យស្នើសុំត្រូវដាក់ជូន **គ.ម.ក.** នូវឯកសារដូចខាងក្រោម÷

១- ពាក្យស្នើសុំបំពេញតាមទម្រង់កំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

២- ឯកសារផ្តល់ព័ត៌មានដូចមានចែងក្នុងប្រការ ១១ នៃប្រកាសនេះ។

៣-ឯកសារភ្ជាប់ដូចខាងក្រោម÷

ក-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ខ-លក្ខន្តិកៈក្រុមហ៊ុន ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

គ-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្របំណុល សម្រាប់វិនិយោគិនគុណវុឌ្ឍិ។

ឃ-លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោ-គិនគុណវុឌ្ឍិ។

ង-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

ច-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការច្បាប់ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ពី **គ.ម.ក.**។

ឆ-កិច្ចព្រមព្រៀងធានាទិញ ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ ឬលិខិតអះអាងពីការចុះកិច្ចព្រមព្រៀងធានាទិញ (Engagement Letter) ជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រក្នុងករណីមិនទាន់ចុះកិច្ចព្រមព្រៀងធានាទិញ។

ជ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់-ងារទូទាត់ ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

ឈ-របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសង ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** (ប្រសិនមាន)។

ញ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារវាយតម្លៃលទ្ធភាពសង ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ (ប្រសិនមាន)។

ដ-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។ ករណីការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិដែលជាវិនិយោ-គិនស្ថាប័ន បុគ្គលដាក់ពាក្យស្នើសុំអាចដាក់ជូន **គ.ម.ក.** នូវកិច្ចព្រមព្រៀងជាមួយភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ប្រសិនមាន។

ឋ-កិច្ចព្រមព្រៀងវិនិយោគចម្រុះសំខាន់ៗ (ប្រសិនមាន)។

ឌ-សេចក្តីថ្លែងអំពីការរឹតត្បិតក្នុងការផ្ទេរមូលបត្របំណុល (Transfer Restriction)។

ឍ-វិញ្ញាបនបត្របញ្ជាក់កាតព្វកិច្ចពន្ធ។

ណ-ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានវត្ថុធានា បុគ្គលនោះត្រូវភ្ជាប់នូវឯកសារបន្ថែមដូចខាងក្រោម÷

-ភស្តុតាងអំពីវត្ថុធានា។

-វិញ្ញាបនបត្របញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបញ្ជាក់ថាវត្ថុធានានោះមិនជាប់ប្រាតិភោគណាមួយឡើយ។

-របាយការណ៍ស្តីពីការវាយតម្លៃទ្រព្យសកម្មដែលចេញដោយក្រុមហ៊ុនវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។

ត-ករណីបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា បុគ្គលនោះត្រូវភ្ជាប់នូវឯកសារបន្ថែមដូចខាងក្រោម÷

-របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

-កិច្ចព្រមព្រៀងជាមួយបុគ្គលធានា។

ថ-ឯកសារផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៣

## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ

### ប្រការ ១១.- ឯកសារផ្តល់ព័ត៌មាន

ឯកសារផ្តល់ព័ត៌មានត្រូវមានមាតិកាអប្បបរមាដូចខាងក្រោម÷

១-សេចក្តីថ្លែងអំពីការរឹតត្បិតក្នុងការផ្ទេរមូលបត្របំណុល។

២-សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន។

៣-ព័ត៌មានស្តីពីសំណើបោះផ្សាយលក់មូលបត្របំណុល។

៤-ព័ត៌មានស្តីពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្របំណុល។

៥-ព័ត៌មានស្តីពីក្រុមហ៊ុនបោះផ្សាយមូលបត្រ រួមទាំងព័ត៌មានស្តីពីប្រតិបត្តិការ។

៦-ព័ត៌មានស្តីពីកត្តាហានិភ័យ។

៧-ព័ត៌មានស្តីពីអភិបាលកិច្ចសាជីវកម្ម។

៨-ព័ត៌មានហិរញ្ញវត្ថុ និង/ឬព័ត៌មានហិរញ្ញវត្ថុរួម។

៩-ឧបសម្ព័ន្ធ។

ឯកសារផ្ដល់ព័ត៌មានត្រូវមានសេចក្ដីបញ្ជាក់ថា *"ព័ត៌មានដែលមាននៅក្នុងឯកសារផ្ដល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្ដល់ព័ត៌មាននេះ"*។

**ប្រការ ១២.- ឧបសម្ព័ន្ធនៃឯកសារផ្ដល់ព័ត៌មាន**

ឯកសារផ្ដល់ព័ត៌មានត្រូវមានភ្ជាប់មកជាមួយនូវឯកសារជាឧបសម្ព័ន្ធដូចខាងក្រោម÷

១-លក្ខខណ្ឌលម្អិតនៃមូលបត្របំណុល។

២-របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ។

៣-របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ (ប្រសិនមាន)។

៤-របាយការណ៍សង្ខេបនៃចំណាត់ថ្នាក់លទ្ធភាពសងលើក្រុមហ៊ុនបោះផ្សាយមូលបត្រ ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** (ប្រសិនមាន)។

៥-របាយការណ៍សង្ខេបស្ដីពីការវាយតម្លៃទ្រព្យសកម្ម (ប្រសិនមាន)។

៦-របាយការណ៍សង្ខេបនៃចំណាត់ថ្នាក់លទ្ធភាពសងលើបុគ្គលធានា ដែលចេញដោយភ្នាក់ងារវាយ-តម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ករណីសំណើបោះផ្សាយលក់សញ្ញាបណ្ណមានបុគ្គលធានា (ប្រសិនមាន)។

៧-លិខិតយល់ព្រមឱ្យធ្វើការផ្សព្វផ្សាយសេចក្ដីថ្លែង ឬរបាយការណ៍របស់អ្នកជំនាញក្នុងឯកសារផ្ដល់ព័ត៌មាន (ប្រសិនមាន)។

**ប្រការ ១៣.- ការទទួលខុសត្រូវរបស់អ្នកជំនាញ**

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ និងភាគីពាក់ព័ន្ធដែលបានផ្ដល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្ដីថ្លែង ឬរបាយការណ៍ ឬយោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្ដល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្ដីថ្លែង របាយការណ៍ ឬយោបល់ដែលបានផ្ដល់ឱ្យនោះ។

**ប្រការ ១៤.- ការផ្ដល់ព័ត៌មានបន្ថែម ព័ត៌មានជំនួស សេចក្ដីបញ្ជាក់ ឬសេចក្ដីបំភ្លឺ**

អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិអំណាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្ដល់ព័ត៌មានបន្ថែម ព័ត៌មានជំនួស សេចក្ដីបញ្ជាក់ ឬសេចក្ដីបំភ្លឺ។ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញតាមការតម្រូវនេះក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីបុគ្គលដាក់ពាក្យស្នើសុំមិនបំពេញបានទៅតាមការតម្រូវខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្រ។

**ប្រការ ១៥.- ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំពីការ

អនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬមិនអនុញ្ញាត ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

**ប្រការ ១៦.- ការបដិសេធលើសំណើបោះផ្សាយលក់មូលបត្របំណុល**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិរបស់បុគ្គលដាក់ពាក្យស្នើសុំ ដោយផ្អែកលើមូលហេតុដូចខាងក្រោម÷

១- បុគ្គលដាក់ពាក្យស្នើសុំមិនបំពេញលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ ឬប្រកាសនេះ។

២- ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈមិនពេញលេញ ក្លែងបន្លំ ឬនាំឱ្យយល់ខុស ឬមានរំលងព័ត៌មានសំខាន់ផ្សេងទៀត។

៣- បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤- ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល។

៥- បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ÷

ក- មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមមាត្រា ៤២ នៃអនុក្រឹត្យ។

ខ- បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ- បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ- ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង- ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបានក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាត។

៦- អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧- ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨- នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ÷

ក- អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ របស់បុគ្គលដាក់ពាក្យស្នើសុំមិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ- មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៩- ការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំនឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

## ជំពូកទី ៤
## ការដាក់លក់មូលបត្រកម្ចីសម្រាប់វិនិយោគិនគុណវុឌ្ឍិ

### ប្រការ ១៧.- ការធ្វើបរិវិសកម្ម

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មមូលបត្របំណុលត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាពសម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មមូលបត្របំណុលត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មមូលបត្របំណុលនោះភ្លាមមក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងដោយវិនិយោគិនគុណវុឌ្ឍិតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា **១៧** នៃអនុក្រឹត្យ និងប្រកាសស្តីពីវិនិយោគិនគុណវុឌ្ឍិក្នុងវិស័យមូលបត្រ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជ ដោយអនុលោមតាមមាត្រា ១៨ នៃអនុក្រឹត្យ។ បញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មមូលបត្របំណុលត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មនឹងត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មបានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤ “ខ” នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ២១ ប្រការ ២២ និងប្រការ ២៣ នៃប្រកាសនេះ។

### ប្រការ ១៨.- ការធ្វើបរិវិសកម្មមូលបត្របំណុលដែលនៅសល់

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្មមូលបត្របំណុល ករណីមូលបត្របំណុលធ្វើបរិវិស-

កម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវធ្វើបរិវិសកម្មមូលបត្របំណុលដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ទៅឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រ នៅថ្ងៃធ្វើការបន្ទាប់គិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះ-ផ្សាយមូលបត្រត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្របំណុលដែលនៅសល់មក **គ.ម.ក.** ភ្លាម។

## ប្រការ ១៩.- ការបែងចែកមូលបត្របំណុល

ក្រុមហ៊ុនមូលបត្រត្រូវចែកចាយមូលបត្របំណុលក្នុងថ្លៃដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌-មានដែលបានចុះបញ្ជី។

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ឬក្រុមហ៊ុនមូលបត្រ ត្រូវបែងចែក និងបញ្ជូនមូលបត្របំណុលទៅឱ្យអ្នកដែលបានធ្វើបរិវិសកម្មដោយជោគជ័យនៅថ្ងៃធ្វើការបន្ទាប់ គិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្មមូលបត្របំណុល។

## ប្រការ ២០.- ការដាក់ផ្ញើមូលបត្របំណុលនៅប្រតិបត្តិកររក្សាទុកមូលបត្រ

បន្ទាប់ពីធ្វើការបែងចែកមូលបត្របំណុលជូនវិនិយោគិនគុណវុឌ្ឍិ ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវដាក់ផ្ញើមូលបត្របំណុលទាំងអស់ដែលបានបោះផ្សាយនៅប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

## ប្រការ ២១.- ការព្យួរឯកសារផ្តល់ព័ត៌មានដែលចុះបញ្ជីរួច

ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមមាត្រា ២១ នៃច្បាប់។ ករណីនេះ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុល និងត្រូវជូនដំណឹងភ្លាមអំពីការព្យួរនេះទៅដល់អ្នកធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយមូលបត្រនិងក្រុមហ៊ុនមូលបត្រត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មមូលបត្របំណុលថាមានសិទ្ធិដកស្ទីការដែលបានធ្វើឡើងចំពោះសំណើលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងក្រុមហ៊ុនមូលបត្រអាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុលឡើងវិញបន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរឯកសារផ្តល់ព័ត៌មានត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ២២.- ការផ្សព្វផ្សាយអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវផ្សព្វផ្សាយភ្លាមអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់

ព័ត៌មានដល់អ្នកធ្វើបរិវិសកម្មដោយផ្ទាល់ និង/ឬតាមមធ្យោបាយផ្សព្វផ្សាយ ដែលមានការយល់ព្រមពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម÷

១-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-កាលបរិច្ឆេទនៃការសម្រេចលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀប នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ប្រាក់រួច។ ពេលវេលានៃការបង្វិលសងនេះត្រូវធ្វើឡើងយ៉ាងយូរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ២៣.- ការបោះផ្សាយលក់មូលបត្របំណុលមិនទទួលបានជោគជ័យ

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មានអាចត្រូវបានលុបចោលផងដែរក្នុងករណីការបោះផ្សាយលក់មូលបត្របំណុលមិនទទួលបានជោគជ័យ។

## ប្រការ ២៤.- ការរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយលក់មូលបត្របំណុល

ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្របំណុលទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដាច់ដោយឡែកដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ។

## ប្រការ ២៥.- ការបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត

បន្ទាប់ពីបញ្ចប់ការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ ក្រុមហ៊ុនបោះផ្សាយមូលបត្រអាចបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុតដើម្បីចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

# ជំពូកទី ៥

# លក្ខខណ្ឌតម្រូវក្រោយពេលបោះផ្សាយលក់មូលបត្របំណុល

## ប្រការ ២៦.-ការអនុវត្តតាមប្រកាសស្តីពីការបង្ហាញព័ត៌មានសាធារណៈ

ក្រោយពេលបោះផ្សាយលក់មូលបត្របំណុល បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវអនុវត្តការបង្ហាញព័ត៌មានសាជីវកម្មដូចមានចែងក្នុងជំពូកទី ៥ នៃប្រកាសនេះ និងប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម លើកលែងប្រការ ៦ ប្រការ ៧ ប្រការ ៨ ប្រការ ៩ ប្រការ ២១ និងប្រការ ២៣ នៃប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម។

**ប្រការ ២៧.- ព័ត៌មានដែលត្រូវបង្ហាញទាន់ពេល**

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ព័ត៌មានទាន់ពេលជូនវិនិយោគិន តាមរយៈទីផ្សារមូលបត្រប្រតិស្រុតតាមទម្រង់កំណត់ដោយទីផ្សារមូលបត្រប្រតិស្រុត និងចម្លងជូន **គ.ម.ក.** ក្នុងពេលដំណាលគ្នា ករណីមានហេតុការណ៍ណាមួយដូចខាងក្រោម÷

១- នៅពេលមានការកែប្រែលក្ខន្តិកៈក្រុមហ៊ុន។

២- នៅពេលមិនមានលទ្ធភាពបង់ការប្រាក់ និង/ ឬប្រាក់ដើមទៅតាមរយៈពេលនៃការទូទាត់ដូចមានចែងក្នុងលក្ខខណ្ឌនៃមូលបត្របំណុល។

៣- នៅពេលមានការបង់ការប្រាក់ និង/ ឬប្រាក់ដើម។

៤- ករណីមានការសម្រេចពន្យារពេលបង់ការប្រាក់នៃមូលបត្របំណុល។

៥- ករណីមានការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល។

៦- ករណីមានហេតុការណ៍ដែលអាចនឹងបណ្តាលឱ្យមានការរំលាយក្រុមហ៊ុន ឬការសម្រេចជម្រះបញ្ជី ឬរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត។

៧- ករណីមានបណ្តឹងសុំបើកសំណុំរឿងក្ស័យធនទៅតុលាការ។

៨- ករណីមូលប្បទានប័ត្រ ប័ណ្ណសងតាមបញ្ជា ឬរូបិយាណត្តិដែលចេញដោយបុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបានបដិសេធដោយធនាគារ ឬករណីប្រតិបត្តិការណាមួយជាមួយធនាគារត្រូវបានព្យួរ ឬហាមឃាត់។

៩- នៅពេលទិញមកវិញមួយផ្នែក ឬទាំងអស់នូវមូលបត្របំណុលរបស់ខ្លួនពីទីផ្សារបន្ទាប់។

១០- នៅពេលគណនីនៅធនាគារត្រូវបានបង្កក ឬត្រូវបានអនុញ្ញាតឱ្យដំណើរការវិញបន្ទាប់ពីមានការបង្កកគណនីនោះ។

១១- ករណីមានការផ្លាស់ប្តូរ ឬកែប្រែលក្ខខណ្ឌ និង/ ឬទ្រព្យធានានៃមូលបត្របំណុល។ ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវផ្តល់នូវឯកសារពាក់ព័ន្ធនឹងការផ្លាស់ប្តូរ ឬការកែប្រែទាំងនេះក្នុងរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ។ ការផ្លាស់ប្តូរ ឬការកែប្រែទាំងនេះ ត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំម្ចាស់មូលបត្របំណុល ដោយត្រូវបញ្ជាក់ពីមូលហេតុនៃការផ្លាស់ប្តូរ ឬការកែប្រែ និងវិបាកដែលកើតមាន ឬអាចនឹងកើតមានចំពោះការសម្រេចចិត្តរបស់ម្ចាស់មូលបត្របំណុល។

១២- នៅពេលមានហេតុការណ៍ ឬព័ត៌មានដែលអាចមានឥទ្ធិពលលើបុគ្គលចុះបញ្ជីលក់មូលបត្រ និង/ ឬមានឥទ្ធិពលលើទំនុកចិត្តឥណទាន (Credit Worthiness) របស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

នៅពេលហេតុការណ៍ណាមួយដូចបានរៀបរាប់ក្នុងកថាខណ្ឌទី១ ខាងលើ បានកើតឡើងលើកលែងចំណុច ១១ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ព័ត៌មាននៃហេតុការណ៍នោះជូនទីផ្សារមូលបត្រប្រតិស្រុត និងចម្លងជូន **គ.ម.ក.** ក្នុងពេលដំណាលគ្នា នៅក្រៅម៉ោងជួញដូរ និងយ៉ាងយូរ ១ (មួយ) ម៉ោងមុនម៉ោងអនុវត្តការជួញដូរនៅថ្ងៃបន្ទាប់។

**ប្រការ ២៨.-របាយការណ៍សាមាយិកដែលត្រូវបង្ហាញ**

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំតាមទម្រង់កំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ជូន **គ.ម.ក.** ក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីបញ្ចប់ឆ្នាំជាប់ពន្ធ ឬក្នុងរយៈពេលសមស្រប ណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។ លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ព័ត៌មានដែលត្រូវបង្ហាញក្នុងរបាយការណ៍ប្រចាំឆ្នាំ រួមមាន÷

១- ព័ត៌មានទូទៅរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលទាំងព័ត៌មានធុរកិច្ចតាមផ្នែក។

៣- សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ដោយរួមបញ្ចូលទាំងការវាយតម្លៃរបស់ក្រុមប្រឹក្សាភិបាលលើទស្សនវិស័យរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៤- របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ។

៥- ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិនតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.**។

ក្នុងគោលដៅផ្ទៀងផ្ទាត់ និងត្រួតពិនិត្យរបាយការណ៍ប្រចាំឆ្នាំ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ជូន **គ.ម.ក.** ក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ នូវរបាយការណ៍របស់អ្នកគ្រប់គ្រង (Management Letter) បន្ទាប់ពីទទួលបានពីសវនកររឯករាជ្យសម្រាប់ប្រើប្រាស់ផ្ទៃក្នុង។ **គ.ម.ក.** មានសិទ្ធិតម្រូវឱ្យបុគ្គលចុះបញ្ជីលក់មូលបត្រធ្វើការពន្យល់ ផ្តល់ឯកសារពាក់ព័ន្ធ និង/ឬកែតម្រូវ ពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់មន្ត្រីដើម្បីត្រួតពិនិត្យដល់ទីកន្លែងពាក់ព័ន្ធនឹងឯកសារ និង/ឬបញ្ជីគណនេយ្យ។

របាយការណ៍ប្រចាំឆ្នាំដែលដាក់ជូន **គ.ម.ក.** ត្រូវមានចុះកាលបរិច្ឆេទច្បាស់លាស់ និងមាននិទ្ទេសថា “***បានអាន និងឯកភាព***” ហើយត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬបុគ្គលដែលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុនដោយត្រូវភ្ជាប់មកជាមួយនូវលិខិតផ្ទេរសិទ្ធិ។

**ប្រការ ២៩.-ការផ្តល់ឯកសារចាំបាច់ និងការចុះត្រួតពិនិត្យដល់ទីកន្លែង**

ទីផ្សារមូលបត្រប្រតិស្រុត ឬអគ្គនាយកនៃ **គ.ម.ក.** អាចស្នើសុំឱ្យបុគ្គលចុះបញ្ជីលក់មូលបត្រផ្តល់ឯកសារចាំបាច់ និង/ឬអាចចុះធ្វើការត្រួតពិនិត្យដល់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានសាជីវកម្មដែលផ្តល់ដោយបុគ្គលចុះបញ្ជីលក់មូលបត្រ ឬដើម្បីពង្រឹងការអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងប្រកាសនេះ និងប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម។ ករណីនេះ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់កិច្ចសហការ និងផ្តល់ឯកសារដោយគ្មានការយឺតយ៉ាវ។

**ប្រការ ៣០.- កាតព្វកិច្ចជូនដំណឹងរបស់ទីផ្សារមូលបត្រប្រតិស្រុត**

ករណីបុគ្គលចុះបញ្ជីលក់មូលបត្របានប្រព្រឹត្តបំពានកាតព្វកិច្ចផ្តល់ព័ត៌មាន ដូចមានចែងក្នុងប្រការ ២៩ នៃប្រកាសនេះ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ទីផ្សារមូលបត្រប្រតិស្រុតត្រូវជូនដំណឹងដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរជាបន្ទាន់ជូន **គ.ម.ក.** ដើម្បីពិនិត្យ និងចាត់វិធានការដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៣១.- កាតព្វកិច្ចរាយការណ៍អំពីការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល**

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** អំពីការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ហើយបន្ទាប់ពីទទួលបានការអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវដាក់ជូន **គ.ម.ក.** នូវកិច្ចព្រមព្រៀងភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលថ្មីក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទតែងតាំង។

## ជំពូកទី ៦

## កម្រៃសេវាក្នុងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

**ប្រការ ៣២.- ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មាន**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅពេលដាក់ពាក្យស្នើសុំឱ្យ **គ.ម.ក.** ជាប្រាក់ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល។

**ប្រការ ៣៣.- សោហ៊ុយសិក្សាសំណុំឯកសារចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស**

បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស ត្រូវបង់សោហ៊ុយសិក្សាសំណុំឯកសារនៅពេលដាក់ពាក្យស្នើសុំឱ្យ **គ.ម.ក.** ជាប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល។

**ប្រការ ៣៤.- ការមិនប្រគល់ត្រឡប់វិញនូវថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារ**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំឯកសារ ដូចមានចែងក្នុងប្រការ ៣២ និងប្រការ ៣៣ នៃប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយទោះជាឯកសារផ្តល់ព័ត៌មានមិនទទួលបានការអនុញ្ញាត និងចុះបញ្ជីក៏ដោយ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**ប្រការ ៣៥.- វិធានការរដ្ឋបាល**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

១- ការព្រមាន ឬដាស់តឿន។

២- ការបង្គាប់ឱ្យដាក់អនុស្សារណៈ។

៣- ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤- ការដាក់កំហិតលើការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ។

៥- ការតម្រូវឱ្យបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦- ការប្រកាសជាសាធារណៈនូវទណ្ឌកម្មរបស់បុគ្គលដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧- ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ ឬការចែកចាយបន្ទាប់។

**ប្រការ ៣៦.- វិធានការផាកពិន័យអន្តរការណ៍**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយមូលបត្រ ឬក្រុមហ៊ុនធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**ប្រការ ៣៧.- ការចេញគោលការណ៍ណែនាំ**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ៣៨.- បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៣៩.- ការអនុវត្ត**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអាទិត្យ ១៥កើត ខែបឋមាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ